តើអ្នកជឿលើរឿងអបិយជំនឿ មន្តអាគម ខ្មោចព្រាយបិសាចដែរឬទេ? បើជឿ តើជឿកម្រិតណាដែរ? ចុះអ្នកធ្លាប់ឮអ្វីខ្លះទាក់ទងនិងរឿងអស់នេះ?

ខ្ញុំឈ្មោះរមនា ជាកូនស្រីរបស់លោកឥន តារា និងភរិយាសាវ៉ាយ ស៊ីលៀប ដែលយើងចួបគ្នាម្តងរួចហើយក្នុងរឿងអណ្តូងខាងលិច.....

================

«រឿងអ្នកសំលៀងកាំបិតនេះ ម៉ាក់មិនចង់និយាយទេកូន! ប៉ុន្តែហួសហេតុពេក!»

ម្តាយខ្ញុំនិយាយប្រាប់ខ្ញុំថា អ្នកសំលៀងកាំបិតម្នាក់ ដែលមានភ្នែកក្រហមៗទឹកមុខកាចៗ សក់ដាញ់ទាំងដុំៗ ដំបូងមើលទៅគួរអាណិតក្នុងសភាពជាអ្នកខ្វះចំណីអាហារតោកយ៉ាក ប៉ុន្តែតាមពិតជាគ្រូមន្តអាគម អូមអាមដែលបណ្តាលឱ្យអ្នកផ្ទះជិតខាងឈ្មោះហុក មានបញ្ហាអកុសលកើតឡើងជាទម្ងន់។

ខ្ញុំនៅស្ងៀមរង់ចាំស្តាប់គាត់បន្ត។

ម្តាយខ្ញុំជាស្ត្រីទំនើបមួយរូប។ ប្រសិនមិនមែនគ្រួសារយើងធ្លាប់ជួបរឿងអាគមខ្មៅផ្ទាល់ភ្នែកកាលពីខ្ញុំនៅក្មេង និងបានធ្វើដំណើរទៅបោះជំរុំក្បែរតំបន់មួយដែលគេឱ្យឈ្មោះថា ផ្ទះព្រានព្រៃនៃអណ្តូងខាងលិចនោះទេ ថ្ងៃនេះពាក្យអូមអាមនឹងមិនមានក្នុងវចនានុក្រមរបស់អ្នកម្តាយខ្ញុំឡើយ។

«កាលកូនឯងនៅរៀននៅស្រុកគេ ផ្ទះប៊ុនហុកមិនដែលមានរឿងអីកើតឡើងទេ! ស្រាប់តែអាទិត្យមុននេះ គាត់ថាឃើញអ្នកសំលៀងកាំបិតនេះមកដល់មុខផ្ទះគាត់ ដើរឆ្លេឆ្លាចុះឡើងមិនព្រមទៅណាសោះ អាការៈដូចជាស្រេកឃ្លានហេវហត់ គាត់ប្រាប់ម៉ាក់ថាកាំបិតគាត់ក៏នៅមិនទាន់រិលផង តែគាត់ឃើញអាណិត ក៏ហៅឱ្យមកសំលៀងកាំបិតឱ្យគាត់ គាត់ឱ្យទឹកហូប ព្រមទាំងឱ្យលុយមួយចំនួន ប៉ុន្តែអ្នកនោះមិនព្រមយកសោះ!»

«ហេតុអីបានជាគាត់មិនយកលុយ?!»

«គឺមានម៉េច គាត់ចង់ទារជម្រិតច្រើនហ្នឹងណ៎ា!»

ខ្ញុំនៅស្ងៀម ប៉ុន្តែមានអារម្មណ៍ថាអ្វីម្យ៉ាងផ្តើមមកសណ្ឋិតនៅក្នុងកែវភ្នែករបស់ខ្ញុំ។ មនុស្សម្នាក់នោះមានសក់ដាញ់ដុំៗ ភ្នែកក្រហមៗ លេចឡើងមកទាំងមិនដែលខ្ញុំទើបចុះពីយន្តហោះមក និងមិនធ្លាប់បានចួបព្រឹត្តិការណ៍នោះផ្ទាល់សោះ។

«កូនដឹងអត់រមនា? គាត់ទារលោកបងហុកដល់ទៅហាសិបដុល្លារ!»

«ហាសិបដុល្លារថ្លៃសំលៀងកាំបិត?» ខ្ញុំហួសចិត្ត។

«ត្រូវ! គ្មានអ្នកណាគេឱ្យគាត់សំលៀងកាំបិតបួនប្រាំ ហើយបង់លុយម្ភៃម៉ឺនរៀលនោះទេកូន! ម្ចាស់ផ្ទះបានទាស់ទែងគ្នាជាមួយគាត់រហូតដល់ផ្អើលអ្នកជិតខាង! ម៉ាក់ក៏បានចេញទៅមើលដែរ ប៉ុន្តែដោយសារនៅកន្លែងធ្វើការគេទូរសព្ទមក ម៉ាក់ក៏ប្រញាប់ចូលក្នុងទូរសព្ទវិញ មិនបានតាមដានតទៅទៀត! អ្នកដែលគេដឹងគ្រប់គ្នា ហួសចិត្តថាអ្នកសំលៀងកាំបិតម្នាក់នោះមិនសុខចិត្ត នៅតែដើរចរច្រប់ចុះឡើងៗរអ៊ូទាមទារយកលុយម្ភៃម៉ឺននោះឱ្យខាងតែបាន រហូតដល់អ៊ំហុកឯងគាត់មិនសុខចិត្តក៏ឱ្យកូនជិះកង់ហៅខាងសង្កាត់ ឱ្យគេចុះមកបណ្ដេញចេញ! ខាងសង្កាត់គេមកដល់និយាយសម្រួលយ៉ាងណាក៏តាម្នាក់នោះដូចជានិយាយមិនដឹងទិសតំបន់ មិននិយាយហេតុផលគិតពីទាមទារលុយម្ភៃម៉ឺនរៀល!»

«ពួកគាត់មិននិយាយថ្លៃគ្នាមុនមែនទេ?»

«ទោះបើយើងមិននិយាយថ្លៃគ្នាមុនក៏បាន ពីព្រោះការសំលៀងកាំបិតមិនដែលលើសពីតម្លៃពីរពាន់រៀលទេកូន! ច្រើនណាស់មួយថ្លៃមួយដុល្លារចុះ ប្រាំកាំបិតថ្លៃប្រាំដុល្លារចុះ ប៉ុន្តែក្រោយមកណាកូនរឿងដែលធំមិនមែនរឿងលុយទេ!»

«រឿងអីទៅម៉ាក់!»

«គ្មាននរណាដឹងថាក្រោយមកនឹងមានរឿងធំទេ! កូនដឹងទេ មនុស្សភ្នែកក្រឡោតមានសក់ដាញ់ខោអាវរហែករយ៉ីរយ៉ៃនោះ មុនចាកចេញបានព្រមានផ្ទះលោកបងហុកថា ត្រូវប្រយ័ត្ន! នេះចាត់ទុកថាជាមេរៀនមួយដែរកូន ក្រោយមកមិនបានបីថ្ងៃផង ប្រពន្ធអ៊ំហុកចាប់ផ្ដើមឈឺធ្ងន់ហើយបញ្ជូនទៅដល់មន្ទីរពេទ្យ តែពេទ្យរកអីមិនឃើញទាំងអស់ សម្ភាធឈាមបេះដូងអីធម្មតាទាំងអស់ ក៏ឱ្យត្រលប់មកផ្ទះវិញ មិនបានប៉ុន្មានថ្ងៃគាត់ស្លាប់ទៅ! រោង៧ថ្ងៃទើបតែរុះទេណ៎ាកូន! អ្នកណាក៏គេដឹងថាគឺជាអំពើរបស់អ្នកសំលៀងកាំបិតម្នាក់នោះដែរ ពីព្រោះគាត់ធ្វើភ្នែកក្រឡែតក្រឡោតខឹងខ្លាំង ដូចជាមានគំនុំគុំកួនតាំងពីពេលណាមកនៅមាត់ទ្វារលោកបងហុកមិនចង់ចេញណាទេ!»

ខ្ញុំស្រាប់តែងុយណាស់ចង់បិទភ្នែក។

ម៉ាក់ដឹងថា ខ្ញុំកំពុងតែធ្វើអ្វីហើយ។ ខ្ញុំជាក្មេងស្រី ដែលមានញាណពិសេសតាំងពីក្មេង។ ចេញទៅរៀននៅស្រុកគេ៥ឆ្នាំមកនេះ សឹងតែភ្លេចថា ខ្ញុំធ្លាប់មានលទ្ធភាពឆ្លើយឆ្លងជាមួយប៉ាខ្ញុំបានច្រើនដងណាស់កាលពីក្មេង។

ប៉ុន្តែមកនៅឯប្រទេសជឿនលឿន ខ្ញុំមិនបានអនុវត្តសមាធិផ្លូវងងឹតអស់ទាំងនេះយូរក្រៃលហើយ។

«ម៉ាក់! អ្វីដែលម៉ាក់និងអ្នកជិតខាងគិត ក្រែងតែផ្ទុយគ្នាពីការពិតដឹង?»

ខ្ញុំលាន់មាត់និយាយបែបនេះទៅកាន់ម៉ាក់ ទាំងភ្នែកនៅបិទ។

ពេលបើកភ្នែកមកវិញឃើញម៉ាក់ខ្ញុំ ដៀងមកសម្លឹងកូនដោយទឹកមុខសង្ស័យមិនជ្រះស្រលះទេ។

«នៅពេលដែលម៉ាក់រំឭកអំពីមនុស្សម្នាក់នោះ ខ្ញុំដូចជាឃើញគាត់នៅក្នុងខួរក្បាលរបស់ខ្ញុំ! តែឈឺក្បាលណាស់ម៉ាក់!»

«ឈប់គិតៗៗ ឈប់គិតភ្លាមរមនា អឺ! ក្រែងថាបន្តិចទៀតមិត្តភក្តិមកឌុបទៅដើរលេងហ្នកូន? ធ្វើយទុកថាមិនបានឮម៉ាក់និយាយអីទាំងអស់! កូនទើបតែមកដល់ស្រុកខ្មែរភ្លាម កុំ…កុំរវើរវាយច្រើន! ណា!»

ជាងសំលៀងកាំបិតម្នាក់នោះ កុំថាឡើយឱ្យកូនស្រីគាត់ស្រមៃនឹកឃើញ សូម្បីតែមកដល់មុខផ្ទះនេះក៏ម៉ាក់បែបមិនចង់ឱ្យកូនងាកទៅសម្លឹងដែរ។

«ឥឡូវនេះ ម្ដាយទើបនឹងស្លាប់មួយហើយ កូនបងបង្អស់របស់លោកបងហុកអាតឹងនោះកូនស្រាប់តែឈឺធ្ងន់ឡើង! អ្នកផ្ទះជ្រួលច្របល់អស់ហើយ! ចូលមន្ទីរពេទ្យ ពេទ្យក៏រកមូលហេតុមិនឃើញដូចគ្នានឹងកាលម្ដាយរបស់គេបេះបិទ!»

«ហើយចាស់ៗអ្នកជិតខាងអីអស់ហ្នឹងបន្ទោសថា ជាស្នាដៃអ្នកសំលៀងកាំបិតម្នាក់នោះទាំងអស់ដែរមែនទេម៉ាក់?»

ម្ដាយខ្ញុំមិនមាត់ ប៉ុន្តែចម្លើយ Yes តាមរយៈទឹកមុខស្រេចហើយ។

ខ្ញុំចាកចេញមកព្រោះមិត្តខ្ញុំមកទទួលហើយ។ ប៉ុន្តែពេលជិះម៉ូតូ ខ្ញុំមិនភ្លេចងាកមកសម្លឹងផ្ទះអ៊ំហុក។ អ្វីម៉្យាងភ្ញោចអារម្មណ៍របស់ខ្ញុំ!

«នីតា! ឈប់!»

ខ្ញុំប្រាប់មិត្តភក្តិខ្ញុំឈ្មោះនីតា ដែលគេមកដឹកខ្ញុំទៅដើរលេងក្រុងភ្នំពេញ។

«ឈប់សិន! បកក្រោយបន្តិច! ចង់ឈប់មុខផ្ទះអ្នកជិតខាងម្នាក់!»

នីតានាងទំនងគិតថាខ្ញុំភ្លេចអ្វីមួយ តែក៏ឆ្ងល់ណាស់ដែលខ្ញុំមិនមែនបកទៅផ្ទះខ្លួន ប៉ុន្តែទៅក្បែររបងអ៊ំហុក។

ម៉ូតូមកឈប់ចំហៀងមួយដែលខ្ញុំអាចសម្លឹងទៅផ្ទះអ៊ំហុកបានច្បាស់។ ពិតណាស់ មិនខុសទេ! ពេលនេះខ្ញុំបានឃើញអ្វីម្យ៉ាងនៅនឹងមាត់ទ្វារ មិនមែនភ្នែកខ្ញុំឡើយគឺចិត្តខ្ញុំ។

រោមដៃខ្ញុំបះ!

បន្ទាប់មក...ខ្ញុំឈានថែមពីរបីជំហ៊ាននិងបន្តសម្លឹងឆ្ពោះទៅក្នុងផ្ទះ។

«ហើយ.....រមនា! មិនទាន់ទៅទេកូនម្ដាយ?!»

ម៉ាក់ខ្ញុំស្រែកសួរមកពីចម្ងាយ។

ខ្ញុំងាកឃើតៗសម្លឹងទៅម្ដាយខ្ញុំ។ ដាស់អារម្មណ៍មួយចម្លែកដល់គាត់ឱ្យទម្លាក់មុខភ័យ....ប្រហែលជាទឹកមុខរបស់ខ្ញុំស្លេកស្លាំងពេក បានជាម្ដាយខ្ញុំត្រូវគាំងនៅពេលសម្លឹងមកកូនលើកនេះ។

ខ្ញុំដកដង្ហើមធំបែរក្រោយដើរសំដៅពូកម៉ូតូរបស់នីតា។ តាមកញ្ចក់ ខ្ញុំឃើញម៉ាក់មិនទាន់ព្រមបកចូលផ្ទះវិញទេ គាត់ប្រហែលជានៅបារម្ភសូម្បីតែខ្ញុំទៅអើតមាត់ទ្វារផ្ទះអ៊ំហុក។

«នីតា! ជំងឺចាស់របស់ខ្ញុំរើវិញហើយ!»

«ឯងឃើញវិញ្ញាណទៀតហើយ?!»

នីតានិយាយជាមួយខ្ញុំទាំងក្ដោបដៃខ្ញុំទាំងសងខាង។ ដៃនាងត្រជាក់ស្រិបឡើងៗ។ ប្រាំឆ្នាំមកហើយដែលខ្ញុំបានចាកចេញពីប្រទេសកម្ពុជាទៅសិក្សានៅប្រទេសបារាំង ជិតពីរពាន់ថ្ងៃមកនោះ ខ្ញុំមិនដែលពាក់ព័ន្ធអ្វីជាមួយរឿងវិញ្ញាណ ឬក៏សូម្បីមើលឃើញ ស្ដាប់ឮអ្វីចម្លែកដែលមនុស្សធម្មតាស្ដាប់មិនឮមើលមិនឃើញ ដូចកាលពីខ្ញុំនៅក្មេងនោះទេ។

មានពេលមួយ ខ្ញុំពិបាកចិត្តខ្លាំងចំពោះរឿងប្រឡង ខ្ញុំក៏សាកលោកបងចង់និយាយមកកាន់ប៉ាខ្ញុំដែរ ប៉ុន្តែបរាជ័យរហូត។

កាលពីក្មេងបើសិនជាខ្ញុំចង់និយាយអ្វីមួយទៅកាន់ឪពុករបស់ខ្ញុំ ខ្ញុំអាចធ្វើបានភ្លាមៗដោយមិនចាំបាច់ប្រឹងច្រើន ប៉ុន្តែនៅពេលដែលខ្ញុំកាន់តែដឹងក្ដីមក អាគមឬក៏សមត្ថភាពសមាធិនេះដូចជាកាន់តែសាបរលាបទៅបន្តិចម្ដងៗគ្មាននរណារកឃើញមូលហេតុពិតឡើយ។

ប្រហែលអាចថា ដោយសារការសិក្សានៅស្រុកគេរវល់ពេក ពីព្រលឹមទល់ព្រលប់ជាមួយការធ្វើដំណើរផ្លូវឆ្ងាយ ស្មុគចិត្តលំបាករឿងភាសាហើយនិងAssignmentច្រើនស្មោកស្មុះ ខ្ញុំសឹងតែគ្មានពេលសម្រាប់ខ្លួនឯងលុបមុខមាត់ស្រួលបួលផង គេងមិនដែលឆ្អែត កុំថាឡើយដល់បង្ហឹកការធ្វើសមាធិ។

ដូច្នេះហើយខ្ញុំគិតថាសមត្ថភាពពិសេសរបស់ខ្ញុំ ចាប់ផ្តើមសាបរលាបពីរមួយថ្ងៃទៅមួយថ្ងៃ។ ទេសកាលអីព្រឹកមិញនេះ.....

«នីតា! ផ្ទះដែលខ្ញុំឱ្យឯងឈប់ម៉ូតូ ដូចជាមានរឿងអ្វីមួយចម្លែក! ខ្ញុំបានឃើញវិញ្ញាណអាក្រក់ដែលនៅតោងរង់ចាំនៅមាត់ទ្វារ!»

នីតាជ្រួញចិញ្ចើមសម្លឹងខ្ញុំរង់ចាំស្តាប់បន្ត ប៉ុន្តែខ្ញុំតឹងចិត្តណាស់ មិនដឹងអធិប្បាយបែបណាឡើយ។ មិនគិតថានីតាសង្ស័យខ្ញុំឆ្កួតទេ ពីព្រោះនីតាជាមិត្តរបស់ខ្ញុំតាំងពីនៅថ្នាក់បឋមមក។

អ្វីដែលខ្ញុំឆ្លងកាត់ក៏គេដឹងទាំងអស់។ ពួកយើងជាមិត្តជិតមួយថ្លើមមួយ សឹងថារឿងដែលខ្ញុំមិនអាចនិយាយប្រាប់នរណាបាន ខ្ញុំអាចនិយាយប្រាប់នាងបាន។

នាងឆាប់យល់ពីប្រធានបទលើកនេះ។ នីតាសម្លឹងខ្ញុំដោយស្ងប់ស្ងាត់ រួចឱនមកខ្សឹបបញ្ជាក់៖

«រមនា! អ្នកផ្ទះនោះកំពុងមានគ្រោះថ្នាក់មែនទេ?!»

«ពិតមែន!»

«ម៉េចឯងចេញមកធ្វើអី? ឯងមិនឆាប់ធ្វើអ្វីម្យ៉ាង ឬប្រាប់ពួកគេទៅ?!»

«ឱ្យខ្ញុំនិយាយពីណាទៅណានីតា? ខ្ញុំក៏រវល់ខ្លួនឯងដែរហ្នឹង! ហើយនីតា ប្រាំឆ្នាំមកនេះខ្ញុំមិនដែលសមាធិបានជោគជ័យទេ សូម្បីស្តាប់ឮពីឆ្ងាយ ឬក៏ប្រើញាណពិសេសនិយាយជាមួយប៉ាខ្ញុំបានសម្រេចសូម្បីម្តងណា! ឥឡូវនេះស្រាប់តែថាមពលចាស់វាវិលវល់មកវិញ? មុនចេញមកនេះម្តាយខ្ញុំប្រាប់ថា ផ្ទះអំហុកអម្បាញ់មិញនេះទើបមនុស្សស្លាប់! ប្រពន្ធគាត់ស្លាប់បានជាង១០ថ្ងៃ ឥឡូវនេះកូនប្រុសរបស់គាត់ឈឺធ្ងន់ទៀត!»

«អូ! រមនាអត់បានទេ រឿងនេះត្រូវតែនិយាយឱ្យបានត្រឹមត្រូវសិនមុនពេលនិយាយឱ្យម្ចាស់ផ្ទះនោះដឹង! តែរមនា! សហគមន៍ខ្មែរយើងប្រាំឆ្នាំមកនេះនៅតែមានអ្នកជឿលើរឿងទាំងអស់នោះច្រើនដដែល!»

«ហ៊ឹម ព្រឹកមិញមុនពេលឯងមកដល់ ម្តាយយើងបាននិយាយរំឭកអំពីអ្នកសំលៀងកាំបិតម្នាក់! គាត់ថាតានោះភ្នែកក្រឡោត សក់ដាញ់សំលៀងកាំបិត ដើរទទូចចុះឡើង មុនផ្ទះមួយដែលមានរឿងនោះ

រហូតដល់អ៊ំហុកគាត់អាណិតទ្រាំមិនបានក៏យកកាំបិតឱ្យធ្វើ ព្រោះគ្មានពីណាគិតថាគាត់នឹងទារថ្លៃសំលៀងដល់ទៅម្ភៃម៉ឺនរៀល ថ្លៃជាងតម្លៃកាំបិតទៅទៀត! អ្នកផ្ទះនោះខឹងខ្លាំងក៏ព្រួតគ្នាបណ្ដេញគាត់ចេញរហូតដល់ឈ្លោះគ្នាទាស់ឮដល់សង្កាត់ អាជ្ញាធរគេចុះមក! អ្នកជិតខាងសុទ្ធតែគិតថាដោយសារតែគំនុំរឿងនោះ មនុស្សមិនស្គាល់អត្តសញ្ញាណដដែលនេះបានដាក់មន្តអាគមអ្វីម្យ៉ាងទៅលើផ្ទះអ៊ំហុក បានជាក្រោយមកមិនបានប៉ុន្មានថ្ងៃប្រពន្ធក៏ឈឺធ្ងន់ហើយស្លាប់!»

នីតាហាក់ស្លុងអារម្មណ៍ស្ដាប់ហើយសួរបកខ្សឹបៗ៖

«ចំណែកឯង ឯងគិតយ៉ាងម៉េច?!»

«ឥឡូវនេះកូនប្រុសច្បងរបស់គាត់ឈឺម្នាក់ទៀតហើយ ពេទ្យក៏រកមិនឃើញមូលហេតុជំងឺដូចគ្នា ប៉ុន្តែយើងសង្ស័យមូលហេតុមួយ!»

ឮប៉ុណ្ណេះនីតាខិតខ្លួនចូលមកកាន់តែកៀកហើយសង្ងើញខ្សឹបខ្សៀវ៖

«សង្ស័យអីទៅរមនា?»

«ពេលឃើញយមរាជបញ្ជូនសេនាមករង់ចាំយកវិញ្ញាណនៅមាត់ទ្វារ យើងនេះគិតភ្លាមពីរឿងធ្វើម៉េចដើម្បីជួយម្នាក់នោះបានវិញ ហើយត្រង់ណេះខ្ញុំគិតថា អ្នកសំលៀងកាំបិតម្នាក់នោះ អាចថាគិតដូចខ្ញុំអ៊ីចឹង!»

«ឯងគិតថា...»

ខ្ញុំបានវិលទៅផ្ទះវិញដោយមិនមានអារម្មណ៍កម្សាន្តអ្វីទៀតនោះទេ។ មកដល់កាលណាក៏ឃើញម៉ាក់និងប៉ានៅអង្គុយលើសាឡុងខ្ញុំជម្រាបពួកគាត់ដែរថា ខ្ញុំចង់រកចួបជាមួយអ្នកសំលៀងកាំបិតម្នាក់នោះបន្ទាន់ខ្លាំង។

ម្ដាយខ្ញុំអន់ចិត្ត ហើយស្ដាយក្រោយដែលគាត់រំឭករឿងទាំងនេះប្រាប់ខ្ញុំ។ មិនតែប៉ុននោះ គាត់ថែមទាំងបានហាមប្រាមខ្ញុំ ដាច់ខាតមិនឱ្យនិយាយរំឭករឿងមនុស្សដែលគាត់ទុកស្មើអពមង្គលនេះសាជាថ្មីទៀតដាច់ខាត។

យប់ឡើង ប៉ាខ្ញុំឡើងមកដល់បន្ទប់។

ប៉ាខ្ញុំជាមនុស្សតែម្នាក់គត់ ដែលអាចទាក់ទងជាមួយខ្ញុំបានតាមរយៈញាណកាលពីនៅតូច ដូច្នេះខ្ញុំក៏សួរគាត់ម្ដងទៀតថា

«បើខ្ញុំនិយាយផ្ទុយពីអ្នកទាំងអស់គ្នាអំពីអ្នកសំលៀងកាំបិតនោះ តើប៉ាយល់យ៉ាងណា?»

ខ្ញុំប្រាប់ប៉ាទៀតថា

«បុរសនោះអាចជាអ្នកចេះមន្តអាគមហើយដើរកាត់ទីនេះបានឃើញអ្វីមួយដែលខ្ញុំបានឃើញកាលពីព្រឹក ចំណែករឿងលុយ២០ម៉ឺនរៀលដែលគាត់ទាមទារនោះ អាចថាជា "តម្រូវ" »

«ស្អីទៅ "តម្រូវ" កូន?»

ប៉ាខ្ញុំសួរមកនេះធ្វើឱ្យខ្ញុំផ្អើលនឹងខ្លួនឯងមែន តើខ្ញុំបានពាក្យនេះពីណាមក? ហេតុអ្វីខ្ញុំនិយាយចេញមកបាន? «តម្រូវ»បានន័យថាកិច្ចម្យ៉ាងដែលគេយកមកតស៊ូផ្ទាញ់ជាមួយពួកវិញ្ញាណ ប៉ុន្តែតើខ្ញុំដឹងរឿងនេះពីណាមក បើខ្ញុំខានលេងរឿងផ្លូវងងឹតយូរណាស់មកហើយហ្នឹង?

«ទោះអ៊ីចឹង តើគ្រួសារបងហុកព្រមជឿដែរទេ?»

ប៉ាសួរទាំងជ្រួញចិញ្ចើម។ ចិត្តគាត់មិនដែលចង់ឱ្យកូនលេងល្បែងមន្តអាគមអូមអាមផ្លូវងងឹតអីទេ ប៉ុន្តែនេះជារឿងដែលគាត់ត្រូវទទួលយកពីព្រោះកូនទោលរបស់គាត់ មិនដូចក្មេងផ្សេងដទៃតាំងពីអាយុ៦ឆ្នាំមុនម្ល៉េះ។

«រឿងចំណោទ មិនមែនគ្រួសារអ្នករងគ្រោះទេ គឺជាងសំលៀងម្នាក់នោះ! ខ្ញុំចង់ចួបនិយាយនឹងគាត់សិន ខ្ញុំមានពាក្យខ្លះចង់សួរណ៎ាប៉ា!»

ប៉ាខ្ញុំរឹតតែមិនមាត់មិនក គាត់ពិចារណាចុះឡើង ហើយបកទៅគេងគងថ្ងាសនៅបន្ទប់សាឡុង ចុងក្រោយគាត់បានសន្យានឹងខ្ញុំថា យើងនឹងស្វែងរកអ្នកសំលៀងកាំបិតនោះ។

ខ្ញុំនឹងប៉ាបានចេញម៉ូតូជិះប្រញិបប្រញាប់ដើម្បីស្វែងរកអ្នកសំលៀងកាំបិតនោះ ដោយសាកសួរជាមួយអាជ្ញាធរឃុំសង្កាត់សាកសួរជាមួយអ្នកផ្សេងៗចប់តាមផ្លូវ ប៉ុន្តែហាក់គ្មាននរណាម្នាក់អះអាងថាបានឃើញគាត់នោះទេ។

បែរអ្នកក្បែរៗម្ដុំខ្ញុំ សូម្បីតែនិយាយអំពីគាត់ក៏ពួកគេភ័យខ្លាចញ័ររួញ។

ជំនឿដែលថាគាត់នៅពីក្រោយការដាក់មន្តខ្មៅមកស្លាប់ប្រពន្ធអ៊ំហុក បានក្លាយទៅជារឿងចចាមអារាមពេញទំហឹងនៅរាប់គីឡូម៉ែត្រជុំវិញតំបន់ដែលក្បែរៗខាង។

នៅពេលត្រលប់មកផ្ទះវិញ ខ្ញុំប្រាប់ប៉ាខ្ញុំថា បើសិនជាយើងនៅតែរកបុរសចម្លែកមិនឃើញ ខ្ញុំខ្លាចតែកូនប្រុសច្បងរបស់អ៊ំហុកមិនអាចឆ្លងផុតយប់នេះទេ។

ប៉ាខ្ញុំភ័យណាស់ព្រោះគាត់ជឿខ្ញុំស្លុងហើយមិនមាត់អ្វីទាំងអស់។ ចំណែកម្ដាយខ្ញុំដែលលបតាមដានកាយវិការឪកូនយើងយូរមកហើយក៏គាត់ចូលមកសួរខ្ញុំតាមត្រង់ថា៖

«ម៉ាក់ប្រាប់ហើយថាមនុស្សហ្នឹងគ្រោះថ្នាក់ ហេតុអីបានជាកូនរមនាចង់ចូបគេកូន?»

ខ្ញុំដឹងថាពួកគាត់មានការគិតអគតិអ្វីម្យ៉ាងទៅលើមនុស្សរូបគួរឱ្យខ្លាច ដែលផ្ទុយពីយើង។ ប៉ានិងខ្ញុំពន្យល់ប្រាប់ម្ដាយខ្ញុំរឿងនេះ គាត់ក៏ព្រមអង្គុយស្ដាប់។ ពេលម៉ាក់សម្លឹងមកខ្ញុំរង់ចាំចម្លើយ ចំណែកខ្ញុំមិនដឹងថាត្រូវនិយាយពីណាទៅណារឿងផ្លូវងងឹត ដែលតាមពិតទៅវាជារឿងស្មុគស្មាញពន់ពេក។

វាជារឿងដែលយើងទទួលដឹងដោយអារម្មណ៍ ប៉ុន្តែមិនអាចពន្យល់ច្បាស់លាស់ដូចវិទ្យាសាស្ត្រនោះឡើយ។

ខ្ញុំបានត្រឹមតែនិយាយប្រាប់ម៉ាក់ថា នៅថ្ងៃដែលកូនឱ្យនីតាឈប់ម៉ូតូនៅមុខផ្ទះអ៊ំហុកគឺខ្ញុំបានឃើញវិញ្ញាណចងអាឃាតម្យ៉ាង ខ្ញុំមិនដឹងថាជាព្រលឹងដែលយមរាជបានបញ្ជូនមកឱ្យនៅរង់ចាំយកជីវិតកូនប្រុសច្បងរបស់គាត់ ឬមួយក៏ជាខ្មោចព្រាយបិសាចមកពីខាងណា ដឹងតែថា គេនៅរង់ចាំយកព្រលឹង។

ម្ដាយរបស់ខ្ញុំជ្រុះរបូតសន្លឹកក្រដាសជូតមាត់ពីដៃ។

សភាពតក់ស្លុត បានសន្ធប់មកលើទ្រូងគាត់ ដូច្នេះខ្ញុំមិនសូវដែលចង់ពិគ្រោះរឿងអស់នេះជាមួយគាត់ឡើយកាលពីដំបូងៗ។

ខ្ញុំពន្យល់គាត់ភ្លាមថា កុំឱ្យគាត់គិតទាន់ហន់និងចោទអ្វីៗទៅលើនាក់សំលៀងកាំបិតម្នាក់នោះហើយរឿងលុយទាមទារម្ភៃម៉ឺនរៀល ដូចជាអ្វីម្យ៉ាងមិនប្រក្រតីទេក្នុងគំនិតអ្នកមានបារមីកាន់ដូចជាខ្ញុំ។

ចិត្តខ្ញុំសង្ស័យម្យ៉ាងថា របស់អពមង្គលនោះ បានមកទុំនៅទ្វាររបស់អ៊ំហុកជាយូរមកហើយ ចំណែកអ្នកសក់ដាញ់ដែលដើរកាត់ អាចថាបានឃើញ ចង់ធ្វើជាអ្នកសង្គ្រោះ។ គាត់អាចចេះផ្លូវងងឹតមើលឃើញរឿងទាំងនោះ បានជាគាត់ចង់សង្គ្រោះអ្នកផ្ទះនោះ។

ម្ដាយខ្ញុំចងចិញ្ចើមងាកមកសម្លឹងខ្ញុំទាំងគ្មានសំណួរ។ ប៉ាខ្ញុំវិញគាត់ដកដង្ហើមធំក្រពាត់ដៃដើរចុះឡើង។ ខ្ញុំយល់ថា រឿងដែលទាក់ទងជាមួយជីវិតមនុស្សគឺជារឿងធំណាស់ ហើយពិសេសជាអ្នកជិតខាងរបស់យើង។ សំខាន់យើងមិនដឹងថាដើមចមនៃរឿងនេះគឺជាអ្វី តើយើងមានលទ្ធភាពអ្វីទៅជួយពួកគេ?

ខ្ញុំកើតមកលើលោកនេះមានញាណពិសេសតាំងពីអាយុប្រាំមួយឆ្នាំ។ ប៉ាខ្ញុំបានប្រាប់ខ្ញុំថា ខ្ញុំជាមនុស្សដែលឋានលើបញ្ជូនមក ឱ្យដឹងហេតុ ដើម្បីជួយសង្គ្រោះមនុស្សម្នានាខានកណ្ដាលនេះ។ វាគឺជាទម្លាប់និងជំនឿនៅក្នុងសាសនារបស់យើង ប៉ុន្តែក្រោយមកខ្ញុំក៏ចេញទៅរៀននៅស្រុកគេ ខ្ញុំមិនដែលប៉ះពាល់រឿងទាំងអស់នេះម្ដងណាទៀតទេ។

ទោះបីយ៉ាងណា ខ្ញុំបានដឹងនិងស្គាល់ក្មេងប្រុសជំទង់ពីរនាក់ដែរកាលរៀននៅប្រទេសបារាំង។

អ្នកដំបូងគឺកូនសេដ្ឋីឥណ្ឌាម្នាក់ដែលមានញាណពិសេស ដឹងរឿងកើតឡើងទៅអនាគតបាន ចំណែកអ្នកទីពីរគឺជាជនជាតិអេស្ប៉ាញជាកូនប៉ូលិស។

ខ្ញុំចួបពួកគេតែពីរដងគត់ តែនិយាយគ្នាដឹងរឿងច្រើនអំពីភាពមិនប្រក្រតីរបស់ពួកយើង។

មុនពេលគាត់ទទួលសញ្ញាបត្រហើយចាកចេញពីសាលានោះ យើងបានញុំាកាហ្វេនិងនិយាយគ្នាបង្ហើយ។ វីឌីគេជាមនុស្សដែលអាចទប់ស្កាត់ មិនឱ្យឧប្បត្តិហេតុអាក្រក់កើតឡើង តាមរយៈការប្រើសរសៃសក់របស់គេ។ រឿងដែលអស្ចារ្យគឺសក់គាត់មិនអាចដុះថែមទៀតនោះទេ តែក៏មិនជ្រុះសូម្បីមួយសសៃណាដែរ លើកលែងតែគាត់សូត្រធម៌មកបណ្ដាច់។

បើគេចេះតែដកវាឡើងម្ដងមួយសរសៃម្ដងមួយសរសៃដើម្បីសង្គ្រោះពិភពលោកនេះ ក្បាលវីឌីអាចនឹងអស់សក់រលីងនៅថ្ងៃណាមួយ ហើយយើងមិនដឹងថា នឹងមានអ្វីកើតឡើងចំពោះគេនោះឡើយ។

ខ្ញុំបិទភ្នែកហើយរៀបចំខ្លួនដូចជាអង្គុយសមាធិ។

ប៉ានិងម៉ាក់មិនបានព្យាយាមហាមឃាត់ឬរំខានខ្ញុំទេ។

ខ្ញុំហៅរកក្មេងប្រុសឥណ្ឌាឈ្មោះម៉ូស្ដា។

«ម៉ូស្ដាៗៗ!»

ឪពុកម្ដាយខ្ញុំដើរទៅបិទទ្វារផ្ទះ។ នេះគឺជាទម្លាប់របស់ខ្ញុំកាលពីក្មេងនៅពេលដែលខ្ញុំភាវនាប្រើសំឡេងនិយាយទៅកាន់នរណាម្នាក់នៅឆ្ងាយ គឺខ្ញុំមានអាការៈដូច្នេះឯង។

ដំបូងឡើយម្ដាយខ្ញុំគាត់ខឹងណាស់។ ម៉ាក់ជាស្ត្រីដែលមានមុខមាត់ម្នាក់នៅក្នុងសង្គមពាណិជ្ជកម្មកម្ពុជា ប្រសិនកុំតែគ្រួសារខ្ញុំចួបរឿងមួយចំនួននៅក្បែរអណ្ដូងខាងលិចក្នុងដំណើរបោះជំរំមួយ ម្ដាយខ្ញុំមិនព្រមជឿលើរឿងទាំងនេះនោះទេ។

មិនដឹងយ៉ាងម៉េច រាងកាយរបស់ខ្ញុំហាក់ចង់ធ្វើសមាធិទោះបីខានធ្វើយូរណាស់មកហើយ។

អ្វីៗដែលធ្លាប់កើតឡើងជាមួយខ្ញុំកាលពីក្មេងបានសន្ធប់រំឭកមកវិញ។ ពេលដែលគ្រាន់តែបិទភ្នែកគ្រីប ខ្ញុំស្រមៃឃើញស្នូរសំលៀងកាំបិតឆ្វេចឆ្វាចនៅចំពោះមុខផ្ទះអ៊ំហុក។ ស្នូរសំឡេងសំលៀងកាំបិតពិតជាលាន់សឺងតែរង្គើដល់បេះដូងរបស់ខ្ញុំ សង្កៀរណាស់ត្រចៀកទាំងសង។

មាត់ខ្ញុំនៅតែស្រែកម៉ូស្តាៗៗៗ

ខ្ញុំរកមិនឃើញក្មេងតណ្ហានោះទេ! ខ្ញុំទាក់ទងគេមិនបានឡើយ! មិនដឹងថា គេកំពុងជាប់រវល់អ្វីឬក៏មានធុរៈអ្វី ប៉ុន្តែខ្ញុំចេះតែស្រមៃឃើញមនុស្សសក់ដាញ់នឹងភ្នែកលៀនដែលម្តាយខ្ញុំប្រាប់មកខ្ញុំ ទាំងខ្ញុំមិនស្គាល់ឈ្មោះគាត់។ ពុំនោះខ្ញុំហៅរកគាត់តាមសមាធិនេះទៅហើយ។

វាគឺជាអាថ៌កំបាំងនៅក្នុងការសមាធិរបស់ខ្ញុំ។

បើខ្ញុំមិនអាចស្គាល់ឈ្មោះគាត់ ខ្ញុំមិនអាចរកគាត់ឃើញតាមញាណឡើយ។ ខ្ញុំចង់ប្រាប់ថា ឈ្មោះដែលម្តាយឪពុកយើងបានឱ្យមកជាកម្មសិទ្ធិក្រៅកាយដំបូងគេក្នុងជីវិតយើងសំខាន់ខ្លាំងណាស់ វាជាអាយុសង្ខារព្រេងវាសនានិងទំនាក់ទំនងរវាងយើងជាមួយចក្រវាឡទឹកដីភ្លើងខ្យល់។

ឈ្មោះយើងម្នាក់ៗសរសេរខ្លីមែន តែគេអាចយកវាទៅធ្វើអ្វីៗឱ្យយើងចុំច្ចើង ឬចេតនាបំផ្លាញជតារាសីយើងបានដូចគ្នា។

«រមនា! រឿងនេះឯងមិនអាចដោះស្រាយបានទេ» ម៉ូស្តានិយាយមកកាន់ខ្ញុំពីចម្ងាយ។ ហេតុអីគេដឹងថា ខ្ញុំនេះនឹងសួរគេអំពីអ្វី ហើយដឹងថាតើអ្វីទៅដែលខ្ញុំកំពុងតែចង់ដោះស្រាយ?

«ម៉ូស្តា! វាជារឿងពាក់ព័ន្ធជាមួយជីវិតមនុស្ស! តើឯងអាចជួយរកបានទេ ខ្ញុំគ្រាន់តែចង់ដឹងថា មានហេតុអ្វីកើតឡើងចំពោះគ្រួសារនោះ? រឿងនោះពាក់ព័ន្ធអ្វីនឹងអ្នកសំលៀងកាំបិតដែរ?»

«ខ្ញុំអាចមើលបានតែអនាគត ខ្ញុំមិនអាចសម្លឹងវិលត្រលប់ក្រោយបានទេ!»

«អូខេ ជួយខ្ញុំម្តងទៅម៉ូស្តា ខ្ញុំចង់រកមនុស្សម្នាក់ជាអ្នកសំលៀងកាំបិត មានភ្នែកធំៗ សក់ដាញ់ អ្វីដែលគាត់ទាមទារគឺម្ភៃម៉ឺនរៀលលុយខ្មែរ ស្មើទៅនឹងហាសិបដុល្លារអាមេរិក! ម្ចាស់ផ្ទះនោះឈ្មោះអ៊ំហុក នៅរំលងបួនផ្ទះ ពីផ្ទះខ្ញុំ! ប្រពន្ធគាត់ទើបតែស្លាប់បានប្រាំបួនថ្ងៃ! គាត់ កូនប្រុសបួននាក់ ស្លាប់ម្នាក់នៅសល់បីឥឡូវនេះកូនប្រុសច្បងរបស់គាត់ ធ្លាក់ខ្លួនឈឺច្រើនថ្ងៃហើយ ខ្ញុំទទួលអារម្មណ៍ចម្លែកថា បងនោះអានឹងទៅតាមម្តាយគាត់នៅយប់នេះ! ដើរកាត់មុខផ្ទះនោះខ្ញុំមានអារម្មណ៍ថាមានវិញ្ញាណមកប្រតោងមាត់ទ្វាររង់ចាំ! វាកំពុងប្រឆាំងទៅនឹងវត្ថុសក្តិសិទ្ធិទាំងអស់ក្នុងផ្ទះ ដែលកំពុងតែព្យាយាមជួយ

ការពារម្ចាស់ផ្ទះប៉ុន្តែមិនអាចជួយឆ្លងផុតពីយប់នេះទេ ពួកគេអស់ដៃហើយ ម៉ូស្តា! មនុស្សប្រុសសក់ដាច់ម្នាក់នោះមានបំណងចង់ជួយអ្នកផ្ទះនោះមែនទេ? ខ្ញុំមានអារម្មណ៍បែបនេះជាសម្ងាត់ខ្ញុំចង់ដឹងការពិត! តើលុយម្តៃម៉ឺនរៀលពាក់ព័ន្ធអ្វីទៅ?»

ភ្នែកខ្ញុំបើកមកវិញចំណែកម៉ូស្តាមិននៅទេ។ អ្វីដែលគេនិងខ្ញុំទើបនឹងបានសាសង គឺមិនបានហើបមាត់ឡើយ យើងធ្វើសមាធិរកគ្នា។

ក្រោកមកវិញខ្ញុំនៅរង់ចាំគេដោយអត់ធ្មត់។

ទីបំផុតខ្ញុំបើកហ្វេសប៊ុកមកហើយប្រាប់ទៅប៉ាខ្ញុំថា ក្មេងប្រុសឥណ្ឌារកមិនឃើញពីមូលហេតុថែមទាំងមិនដឹងថាមានទំនាក់ទំនងបែបណារវាងអ្នកសំលៀងកាំបិត លុយម្តៃម៉ឺនហើយនិងអ្នកផ្ទះនោះទេ ប៉ុន្តែគេអាចរកឃើញកន្លែងដែលមនុស្សសក់ដាញ់នោះរស់នៅ។

ពុកខ្ញុំអរណាស់ ប៉ុន្តែម្តាយខ្ញុំឃាត់មិនឱ្យខ្ញុំទៅឡើយ។

ពេលនេះម៉ោងបួនរសៀលហើយ មិនប៉ុន្មានទៀតទេមេឃងងឹតមិនខាន។ ទោះជាសភាពបែបនេះម្តាយខ្ញុំគាត់មិនចង់ឱ្យឪកូនយើងទៅពាក់ព័ន្ធ ប៉ុន្តែខ្ញុំបានពន្យល់គាត់ថា យើងមិនដឹងថាបន្ទាប់ពីកូនប្រុសច្បងរបស់អ៊ំហុក នឹងមានអ្នកណាម្នាក់ទៀតឡើយ បើសិនជាយើងបានជួយអស់ពីលទ្ធភាពនៅតែមិនអាចជួយបានគឺជាវាសនារបស់គេ ប៉ុន្តែបើសិនជាយើងនៅរង់ចាំដោយមិនបានធ្វើអ្វីម្យ៉ាងទម្រាំឃើញគេបាត់បង់ទៅម្តងម្នាក់ៗ គឺជាវិប្បដិសារៈដែលយើងហៅមកវិញមិនបាននោះទេ។

ម្តាយខ្ញុំឈរផ្ទឹងស្លេកស្លាំង។

ឪពុកម្តាយខ្ញុំលោកមានតែខ្ញុំម្នាក់ប៉ុននោះ ដូច្នេះអារម្មណ៍នៃភាពបាត់បង់ពិតជាមានឥទ្ធិពលទៅលើស្មារតីរបស់គាត់។

ម្តាយខ្ញុំមិនមាត់ឃាត់ទេ ពេលខ្ញុំចាកចេញពីផ្ទះទៅជាមួយប៉ា ខ្ញុំនៅក្នុងគោលដៅឆ្ពោះរកតំបន់ជាយក្រុងមួយ។

ដូចការស្មានទុក សម្រាប់ឪពុកនិងកូនយើង ការសួរផ្លូវងងឹតពិតជាសំខាន់ណាស់ យើងពិតជាបានរកឃើញមនុស្សសក់ដាញកំពុងតែអង្គុយក្បែរធុងសំរាមស្អុយគគ្រុកមួយ។

គ្មាននរណាគិតថាគាត់ជាមនុស្សមានសតិនោះទេ។

ពួកយើងតម្រង់ទៅរកគាត់ធ្វើឱ្យគ្រប់គ្នាតាមមើល ប៉ុន្តែបុរសនោះមិនតាមមើលយើងឡើយ គាត់ធ្វើដូចជាដឹងនិងមិនខ្វល់ផង។

«ខ្ញុំមិនអាចជួយពួកគេបានទេ វាគឺជាវាសនា» គាត់និយាយបែបនេះធ្វើឱ្យប៉ានិងខ្ញុំសឹងថាលស់ព្រលឹងតែម្តង។

«បើពូមិនព្រមជួយគាត់...! ប្រាប់ខ្ញុំមក ខ្ញុំអាចជួយគាត់បានទេ? ដោយវិធីណាទៅ!»

បុរសនោះងើបមុខសម្លឹងមកខ្ញុំធ្វើឱពុកខ្ញុំភ្ញាក់ទាញខ្ញុំថយក្រោយសឹងតែថាបះដៃជើង ព្រោះភ្នែកគាត់ក្រឡេតៗក្រហមង៉ូវ។

ប៉ាមកឈរពាំងពីមុខខ្ញុំ ដើម្បីការពារខ្លាចបុរសនោះធ្វើអ្វីម្យ៉ាងមកលើខ្ញុំ ទឹកមុខគាត់ពិតជាអាក្រក់ជាងអ្វីដែលអ្នកជិតដិតនានានិយាយ ប៉ុន្តែចិត្តរបស់គាត់គឺល្អជាងអ្វីដែលគ្រប់គ្នាដឹង។ អ្នកសំលៀងកាំបិតគាត់សម្លឹងខ្ញុំពីលើដល់ក្រោមហាក់ភ្ញាក់ផ្អើល ហើយជញ្ជក់មាត់ថា«អស្ចារ្យណាស់»។

ភាពរីករាយភ្លឺស្វាងមួយលេចឡើងក្នុងអារម្មណ៍ខ្ញុំ។

ខ្ញុំស្រាប់តែជឿថា បុរសនេះបានរកឃើញអំណាចអ្វីម្យ៉ាងនៅលើរាងកាយនិងថាមពលពីធម្មជាតិរបស់ខ្ញុំ។

«តើខ្ញុំជួយអ៊ំហុកបានទេ? វិញ្ញាណនៅនឹងមាត់ទ្វារគាត់ជាអ្វីទៅ?»

គាត់មកអូសដៃខ្ញុំទៅក្បែរដើមពោធិ៍ឆ្ងាយពីធុងសំរាមធ្វើឱ្យប៉ាខ្ញុំរត់តាមមិនហ៊ានប្រហែស។

«ក្មួយឯងចង់ជួយគេ?»

ខ្ញុំងក់ក្បាល សម្រាប់ខ្ញុំនិងគាត់ដូចជាមិនចាំបាច់និយាយគ្នាដល់ទៅពីរដងទេ គឺពួកយើងយល់ពីបំណងរៀងខ្លួន។

«អ្នកក្នុងផ្ទះនេះបានប្រមាថពាក្យសម្បថ គេលួចកេងលុយមនុស្សធម៌នៅកន្លែងណាមួយ ហើយធ្វើឱ្យមានមនុស្សស្លាប់តែហោងដោយសារការកឹបកេងនោះ! វិញ្ញាណដែលក្មួយឯងឃើញ នៅមិនព្រមសុខចិត្ត រង់ចាំចងពៀរដល់ពេលដែលរាសីដាក់ក្នុងផ្ទះមានបញ្ហា គេក៏មកទាមទារបំណុលនៅនឹងមាត់ទ្វារ! ខ្ញុំដឹងរឿងនេះពេលខ្ញុំដើរកាត់ ហើយក៏ដាក់ប្រស្នាជាមួយម្ចាស់កម្មពៀរ ថាបើសិនជាអ្នកក្នុងផ្ទះព្រមបរិច្ចាគអ្វី លុយកាក់២០ម៉ឺនរៀល បណ្តាសាទាមទារយកជីវិតនឹងរលាយ!»

«លុយម្ភៃម៉ឺនរៀលថ្នូរនឹងកាំបិតសំលៀង តើនរណាគេឱ្យពូទៅ?! គេគិតថាពូជាមនុស្សលោភ! មនុស្សចួនកាលអាចចង់ធ្វើអំពើល្អប៉ុន្តែគេរើសដែរ»

បុរសនោះនិយាយពន្យល់មួយៗ៖

«ជាមួយនឹងវិញ្ញាណតែហោងទាំងអស់នោះ យើងមិនអាចមានវិធីផ្សេងក្រៅពីប្រថុយទេ! បើសិនជាប្រស្នាងាយដោះ គេមិនហៅថាប្រស្នាប្រតោងជីវិតឡើយក្មេងស្រី!»

«ចុះឥឡូវនេះតើវិញ្ញាណនោះចង់បានមនុស្សប៉ុន្មាននាក់ទៀត?!»

«ខ្ញុំមិនដឹងទេ! ខ្ញុំមានសិទ្ធិធ្វើប្រស្នាជាមួយគេតែម្តងប៉ុននោះ ខ្ញុំចាញ់រួចទៅហើយ ពួកគេបានបណ្តេញខ្ញុំចេញមកហើយ ប្រសិនត្រលប់ទៅទៀតមានតែខ្ញុំស្លាប់!»

«ជួយរកវិធីទៅអ៊ុំចឹងណ៎ាពូ តើខ្ញុំអាចជួយគេបានទេ!»

គាត់លូកដៃបេះយកស្លឹកពោធិ៍ពីរសន្លឹកដែលនៅក្បែរក្បាលបំផុតមក ហើយហុចឱ្យខ្ញុំ៖

«របស់ពីនេះតំណាងឱ្យហេតុផលខ្មៅនិងសនៅលើភពផែនដី នាងតូចត្រលប់ទៅផ្ទះវិញរើសយកមួយ បើសិនជាមួយនោះប្រែជាក្រៀមនៅព្រឹកស្អែកបញ្ជាក់ថា នាងមិនអាចទៅជួយគេបាននោះទេ បិទភ្នែកធ្វើមិនដឹងទៅ តែបើវានៅតែស្រស់ញញឹម ក្មួយអាចធ្វើបានត្រូវប្រាប់ដំណើរដើមទងឱ្យម្ចាស់ផ្ទះឧបកិច្ចបរិច្ចាគលុយខ្លះនិងសារភាពកំហុស!»

ខ្ញុំហើយនិងឪពុកបានវិលត្រលប់មកផ្ទះវិញដោយចងចាំគ្រប់អ្វីដែលគាត់បាននិយាយ។

យប់នោះខ្ញុំមិនទាន់ជ្រើសរើសយកសន្លឹកណាមួយទេព្រោះភ័យពេក។ ខ្ញុំទុកវាទាំងពីរនៅលើតុធ្វើការរបស់ខ្ញុំហើយព្យាយាមសមាធិ។ ប៉ុន្តែមិនអាចទាក់ទងម៉ូស្តាបានរហូត រហូតដល់ពេលដែលខ្ញុំសម្រេចចិត្តបោះស្លឹកពោធិ៍មួយចោលហើយទុកត្រឹមតែមួយគត់ទើបខ្ញុំទាក់ទងម៉ូស្តាបាន។

តើស្លឹកពោធិ៍នោះក្រៀមឬស្រស់នៅព្រឹក?

សួរខ្ញុំបែបនេះ។

«ម៉ូស្តា! ខ្ញុំចង់បញ្ចប់នូវបណ្តាសាខ្មៅលើផ្ទះអ្នកជិតខាងខ្ញុំ!»

«រមនា ឯងគ្មានអានុភាពដល់ម្លឹងទេ ហើយខ្ញុំក៏គ្មានដែរ គ្រប់យ៉ាងគឺជាវាសនា!»

«ឯងចង់និយាយថា ស្លឹកពោធិ៍នោះនឹងប្រែទៅជាខ្មៅមានដែរទេ?!»

«ពេលវេលានិងឆ្លើយនូវសំណួររបស់ឯងរមនា ខ្ញុំមិនអាចនិយាយរឿងនេះប្រាប់ឯងបានទេ!»

«ឯងជាអ្នកដឹងពីអនាគតម៉ូស្តា!»

«ទោះណាជាចក្រវាឡនេះ បានឱ្យអំណាចពិសេសមកឱ្យខ្ញុំ ដើម្បីដឹងបាននូវអ្វីជាមុន ក៏មិនមែន មានន័យថាខ្ញុំត្រូវតែប្រាប់ទៅអ្នកទីពីរនោះដែរ!»

ម៉ូស្តានិយាយថាមិនអាចប្រាប់បាន គឺប្រាកដជាមានហេតុផលរបស់គេហើយ។

ខ្ញុំចូលគេងទាំងរសាប់រសល់ ហើយជារឿយៗតែងតែក្រោកមកលបសម្លឹងបន្ទប់បាយខាងក្រោយនៃជួរផ្ទះរបស់អ៊ំហុក។

ផ្ទះអ៊ំដែលស្ងាត់សូន្យឈឹងនាយប់នេះធ្វើឱ្យខ្ញុំយល់ស្របទាំងស្រងេះស្រងោចថា គ្រប់រឿងរ៉ាវនានា លើលោកពិតជាពេលខ្លះត្រូវបណ្តោយទៅតាមវាសនាកម្ម។

ក្នុងសុបិន ខ្ញុំនៅតែទន្ទេញបែរបន់យ៉ាងណា អង្វរករសុំឱ្យសន្លឹកពោធិ៍របស់ខ្ញុំក្រៀមនៅព្រឹកបន្ទាប់។

ដូចការគិតស្លឹកឈើនេះមិនបានក្រៀមក្រញង់ទេ ខ្ញុំសប្បាយចិត្តដូចខ្លួនឯងបានរស់ឡើងវិញម្តងទៀត។

ខ្ញុំរត់ទៅផ្ទះអ៊ំហុក ហើយចាប់ផ្តើមសុំចូបគាត់។

អ៊ំហុកមានទឹកមុខស្រពោន ព្រោះកូនប្រុសគាត់លែងដឹងខ្លួនកំពុងត្រៀមបញ្ជូនទៅមន្ទីរពេទ្យរង់ចាំឡាន។

ប៉ុន្តែចាស់ៗខ្លះដែលបានមកពីស្រុកគាត់បាននិយាយថា មិនឱ្យបញ្ជូនទៅនៅឱ្យធម៌ល្អជាង។

ខ្ញុំសុំអ៊ំហុកចូបស្ងាត់ៗជាមួយប៉ា ហើយប្រាប់គាត់ថា អ៊ំត្រូវសារភាពថា អ្នកណាក្នុងផ្ទះអ៊ំនេះ ធ្លាប់បានពាក់ព័ន្ធជាមួយរឿងលុយសប្បុរសធម៌ដែលមានបញ្ហាដល់អាយុជីវិតមនុស្ស។

គាត់នៅស្ងៀមទម្លាក់ទឹកមុខ។

គ្រប់គ្នានៅក្នុងភូមិនេះគេដឹងថាខ្ញុំគឺជាក្មេងដែលមានវិញ្ញាណកាន់។

ទោះបីជាខ្ញុំខាននៅទីនេះយូរហើយ ទើបតែត្រលប់មកវិញក៏គាត់ភ្ញាក់ផ្អើលដែរដែលខ្ញុំមកសួរបែបនេះ។

«អ៊ំ! បើសិនជាអ៊ំព្រមសារភាពយើងប្រហែលជាអាចធ្វើរឿងទាំងអស់នោះទាន់!»

គាត់ស្រាប់តែសួរខ្ញុំវិញភ្លាមថា ៖

«ធ្វើយ៉ាងណា?»

ខ្ញុំប្រាប់គាត់គ្រប់យ៉ាងតាមដែលអ្នកសំលៀងកាំបិតបាននិយាយ ហើយក៏ចាប់ផ្តើមអង្គុយភាវនានៅផ្ទះរបស់គាត់ ដូច្នេះការបញ្ជូនកូនប្រុសរបស់គាត់ត្រូវផ្អាក។ ខ្ញុំមានបំណងចង់ចួប និងសួរម្ចាស់ដី(អ្នកជំនាង)ថា តើអ៊ំហុកនឹងត្រូវសារភាពដោយវិធីណា?

ប៉ុន្តែខ្ញុំមិនអាចចួបនឹងអ្នកជំនាងផ្ទះសោះ។ ខ្ញុំកាត់យល់ថា អ្នកជំនាងផ្ទះបានប្រឹងប្រែងអស់ពីលទ្ធភាព ដើម្បីថែរក្សាការពារជុំវិញផ្ទះយ៉ាងហត់នឿយអំពីវិញ្ញាណចងអាឃាតដែលកំពុងសង្វើញចង់យកជីវិត។

សង្គ្រាមនេះបន្លាយជាយូរថ្ងៃមកហើយ។ ខ្ញុំបានបើកភ្នែកមកវិញក្រឡេកទៅឃើញស្និតចេកអ៊ំហុកដាក់ថ្វាយម្ចាស់ដី ខ្ញុំប្រាប់ទៅអ៊ំនេះឱ្យរៀបចំសែនម្ចាស់ទឹកម្ចាស់ដីជាគ្រឿងក្រអូប ទឹកអប់ទៀនធូបដើម្បីបង្កើតថាមពលវិជ្ជមានដល់ ពួកគេក្នុងកិច្ចការពារផ្ទះនេះបន្លាយយកពេលវេលាដោះស្រាយ។

ស្រាប់តែប៉ូលិសមួយក្រុមបានជិះម៉ូតូឈូឆរមកដល់មុខផ្ទះគាត់ ធ្វើឱ្យពួកយើងស្រឡាំងកាំង។ ប៉ូលិសបានប្រាប់យើងថា កូនប្រុសទីពីររបស់គាត់កំពុងជាប់ឃុំ ហើយទំនងជានឹងជាប់ចោទពីបទមនុស្សឃាត។ ពួកយើងពិតជាតក់ស្លុត ពីព្រោះអ្នកដែលត្រូវកូនប្រុសទីពីររបស់គាត់សម្លាប់ គ្មានអ្នកណាក្រៅពីមនុស្សសក់ដាញ់ដែលដើរសំលៀងកាំបិតម្នាក់នោះទេ។

គេបាននាំក្រុមបក្សពួកទៅរកគាត់ឃើញ ហើយក៏វាយសម្លាប់គាត់ ដោយសារតែមិនអាចសួរគាត់ឱ្យសារភាពពីរឿងមន្តអាគមលើបងប្រុសគេនិងម្តាយគេបាន។

នៅល្ងាចដដែលនោះកូនប្រុសច្បងរបស់អ៊ំហុកបានស្លាប់។ ម៉ូស្គានិងអ្នកសំលៀងកាំបិត តាមពិតពួកគេដឹងច្បាស់នឹងបានប្រាប់ខ្ញុំជាមុនហើយ ថាមិនអាចជួយបានទេ។

ហ៊ឹម...

មួយអាទិត្យក្រោយមក ក៏នៅពេលកូនពៅគាត់ធ្លាក់ឈឺ អ៊ំហុកបានមកយំដាក់ម្តាយខ្ញុំ អង្វរខ្ញុំឱ្យរកវិធីជួយ។ ខ្ញុំបានសមាធិ ហើយក៏បានចួបជាមួយអ្នកជំនាញផ្ទះ។

នៅក្រោមការប្រាប់របស់ខ្ញុំ អ៊ំហុកបានធ្វើពិធីសារភាពនិងបរិច្ចាគទ្រព្យសម្បត្តិគាត់ពាក់កណ្តាលទៅឱ្យមូលនិធិមួយចំនួនដែលពាក់ព័ន្ធនឹងការព្យាបាលជំងឺ។

ចាប់ពីពេលនោះមកគាត់ក៏បានរើផ្ទះចាកចេញពីតំបន់នោះ ហើយឮថាកូនប្រុសពៅគាត់បានជាសះឡើងវិញចំណែកគាត់បានកាន់សិល្ប៍ឈប់បម្រើការងារទៀត។

ថ្ងៃមួយម្តាយខ្ញុំបាននាំដំណឹងមកប្រាប់ខ្ញុំថា គ្រួសារអ៊ំហុកនិងកូនប្រុសទាំងពីរមិនមានអ្វីបៀតបៀនទេ តែកូនទីពីររបស់គាត់ត្រូវរស់នៅក្នុងពន្ធនាគារអស់មួយជីវិត។

តាមរយៈរឿងនេះ ខ្ញុំរមនាចង់ប្រាប់អ្នកទាំងអស់គ្នាថា ប្រាក់សប្បុរសធម៌មិនអាចប៉ះពាល់បាននោះទេ ពិសេសសាច់ប្រាក់ដែលទាក់ទងនឹងការធ្វើឱ្យមនុស្សមានជីវិតបន្តឬក៏ស្លាប់។

សូមឱ្យអំពើល្អនៅតែជាវត្ថុដ៏មានតម្លៃនិងជាអាទិភាពនៅគ្រប់កាលៈទេសៈនៃការដោះស្រាយបញ្ហារបស់គ្រប់គ្នាដែលអានរឿងនេះ។